៥-អនុរដ្ឋលេខាធិការក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក

៦-អនុរដ្ឋលេខាធិការក្រសួង កិច្ចការនារី និងអតីតយុទ្ធជន សមាជិក

៧-អគ្គនាយកពន្ធនរដ្ឋាករ នៃក្រសួងសេដ្ឋកិច្ច សមាជិក

៨-អគ្គលេខាធិការរងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងជាអគ្គលេខាធិការ នៃគណៈកម្មាធិការនីតិកម្មរ៉ែ និងអភិវឌ្ឍន៍ អគ្គលេខាធិការ

**មាត្រា ២ .-**

រាល់បទបញ្ញត្តិណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**មាត្រា ៣ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការគ្រប់ក្រសួង និងស្ថាប័នពាក់ព័ន្ធ និងសមាជិកដូចមានចែងក្នុងមាត្រា១ និងអភិបាលខេត្ត-ក្រុង ត្រូវអនុវត្តតាមអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

បានជំរាបជូន

សម្តេចនាយករដ្ឋមន្ត្រី

ហត្ថលេខា

គាត ឈន់

ទេសរដ្ឋមន្ត្រី

រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

អនុប្រធានទី១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ប្រធានគណៈកម្មាធិការដឹកនាំការងារនៃកម្មវិធីសំរេច

★★★

## អនុក្រឹត្យ ២១ អនក្រ.បក

## ស្តីពី ការបង្កើតគណៈកម្មាធិការជាតិទាំង ៦ សំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកជំនាញ

## (Functional Cooperation)

***

### រាជរដ្ឋាភិបាល

-បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា

www.pheakdeylaw.com

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី

-បានឃើញអនុក្រឹត្យលេខ ៣២ អនក្រ.បក ចុះថ្ងៃទី២៥ ខែមិថុនា ឆ្នាំ១៩៩៦ ស្ដីពីការតាក់តាំង និងការប្រព្រឹត្តទៅនៃប្រព័ន្ធសំរបសំរួលថ្នាក់ជាតិ (ICN)

-តាមការឯកភាព ពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ ថ្ងៃទី ២៥ ខែ កុម្ភៈ ឆ្នាំ ២០០០

## សំរេច

**មាត្រា ១ .-**

- បង្កើតគណៈកម្មាធិការជាតិទាំង ៦ សំរាប់កិច្ចសហប្រតិបត្តិការអាស៊ាន ផ្នែកជំនាញ ជាភាសាអង់គ្លេស ហៅថា **(Functional Cooperation)** ក្នុងគោលដៅ ដើម្បីទាញយកផលប្រយោជន៍ ជាអតិបរមា ក្នុងការធ្វើកិច្ចសហប្រតិបត្តិការជំនាញនេះ ពីបណ្ដាប្រទេសអាស៊ាន និងប្រទេសជាដៃគូសន្ទនា **(Dialogue Partners)** ។

**មាត្រា ២ .-**

- គណៈកម្មាធិការជាតិសំរាប់កិច្ចសហប្រតិបត្តិការអាស៊ាន ផ្នែកជំនាញទាំង៦ មានឈ្មោះ និងសមាសភាពដូចតទៅ :

១-គណៈកម្មាធិការជាតិសំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកមុខងារសាធារណៈ**(National Committee on Civil Service)**

| | |
|---|---|
| - ប្រធានស្ថាប័ន ឬ តំណាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ | ប្រធាន |
| - តំណាងលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា | អនុប្រធានប្រចាំការ |
| - តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី | សមាជិក |
| - តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| - តំណាង ក្រសួងមហាផ្ទៃ | សមាជិក |
| - តំណាង ក្រសួងផែនការ | សមាជិក |
| - តំណាង ក្រសួងពាណិជ្ជកម្ម | សមាជិក |

២- គណៈកម្មាធិការជាតិសំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកវប្បធម៌ និង ព័ត៌មាន **(National Committee on Culture and Information)**

| | |
|---|---|
| - ប្រធានស្ថាប័ន ឬ តំណាងក្រសួងព័ត៌មាន | ប្រធាន |
| - ប្រធានស្ថាប័ន ឬ តំណាងក្រសួង វប្បធម៌ និងវិចិត្រសិល្បៈ | អនុប្រធាន |

www.pheakdeylaw.com

- តំណាង អគ្គលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា អនុប្រធានប្រចាំការ
- តំណាង ទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- តំណាង ក្រសួងអប់រំយុវជន និងកីឡា សមាជិក
- តំណាង ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក
- តំណាង ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន សមាជិក
- តំណាង ក្រសួងទេសចរណ៍ សមាជិក
- តំណាង ក្រសួងពាណិជ្ជកម្ម សមាជិក

៣-<u>គណៈកម្មាធិការជាតិសំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកបរិស្ថាន</u> **(National Committee on Environment)**

- ប្រធានស្ថាប័ន ឬ តំណាងក្រសួងបរិស្ថាន ប្រធាន
- តំណាង អគ្គលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា អនុប្រធានប្រចាំការ
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- តំណាង ក្រសួងឧស្សាហកម្មរ៉ែ និងថាមពល សមាជិក
- តំណាង ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- តំណាង ក្រសួង ទេសចរណ៍ សមាជិក
- តំណាង ក្រសួងសាធារណការ និងដឹកជញ្ជូន សមាជិក
- តំណាង ក្រសួងអភិវឌ្ឍន៍ជនបទ សមាជិក
- តំណាង ក្រសួងអប់រំ យុវជន និងកីឡា សមាជិក
- តំណាង ក្រសួងសុខាភិបាល សមាជិក
- តំណាង ក្រសួងកិច្ចការនារី និងអតីតយុទ្ធជន សមាជិក
- តំណាង ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
- តំណាង ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ សមាជិក
- តំណាង ក្រសួងធនធានទឹក និង ឧតុនិយម សមាជិក
- តំណាង ក្រសួងពាណិជ្ជកម្ម សមាជិក

៤-<u>គណៈកម្មាធិការជាតិសំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកប្រយុទ្ធ ប្រឆាំងគ្រឿងញៀន</u>

**( National Committee for Combating Drug )**

- ប្រធានស្ថាប័ន ឬ តំណាងក្រសួងយុត្តិធម៌ ប្រធាន
- អគ្គលេខាធិការ ឬតំណាងអាជ្ញាធរជាតិប្រយុទ្ធប្រឆាំងគ្រឿងញៀន អនុប្រធាន

www.pheakdeylaw.com

- តំណាង លេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា — អនុប្រធានប្រចាំការ
- តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី — សមាជិក
- តំណាង ក្រសួងមហាផ្ទៃ — សមាជិក
- តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — សមាជិក
- តំណាង ក្រសួងអប់រំយុវជន និងកីឡា — សមាជិក
- តំណាង ក្រសួង សុខាភិបាល — សមាជិក
- តំណាង ក្រសួងការពារជាតិ — សមាជិក
- តំណាង ក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា — សមាជិក
- តំណាង ក្រសួងពត៌មាន — សមាជិក
- តំណាង ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ — សមាជិក
- តំណាង ក្រសួងពាណិជ្ជកម្ម — សមាជិក
- តំណាង ក្រសួងទំនាក់ទំនងសភា និងអធិការកិច្ច — សមាជិក
- តំណាង ធនាគារជាតិ — សមាជិក

<u>៥-គណៈកម្មាធិការជាតិសំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកអភិវឌ្ឍន៍សង្គម</u> **(National Committee on Social Development )**

- រដ្ឋលេខាធិការ ឬ តំណាងក្រសួងសង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈ និងយុវនីតិសម្បទា — ប្រធាន
- តំណាង លេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា — អនុប្រធានប្រចាំការ
- តំណាងទីស្ដីការគណៈរដ្ឋមន្ត្រី — សមាជិក
- តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ — សមាជិក
- តំណាង ក្រសួងអប់រំ យុវជន និងកីឡា — សមាជិក
- តំណាង ក្រសួង សុខាភិបាល — សមាជិក
- តំណាង ក្រសួង កិច្ចការនារី និងអតីតយុទ្ធជន — សមាជិក
- តំណាង ក្រសួង អភិវឌ្ឍន៍ជនបទ — សមាជិក
- តំណាង ក្រសួង បរិស្ថាន — សមាជិក
- តំណាង ក្រសួង ឧស្សាហកម្មរ៉ែ និងថាមពល — សមាជិក
- តំណាង ក្រសួង ធនធានទឹក និងឧតុនិយម — សមាជិក
- តំណាង ក្រសួង សាធារណការ និងដឹកជញ្ជូន — សមាជិក
- តំណាង ក្រសួង ផែនការ — សមាជិក
- តំណាង ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ — សមាជិក

www.pheakdeylaw.com

- តំណាង ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
- តំណាង ក្រសួង ពាណិជ្ជកម្ម សមាជិក
- តំណាង ធនាគារជាតិ សមាជិក
- តំណាង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
- តំណាង គណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ សមាជិក
- តំណាង មជ្ឈមណ្ឌលសកម្មភាពកំចាត់មីនកម្ពុជា សមាជិក
- តំណាង អាជ្ញាធរជាតិប្រយុទ្ធប្រឆាំងនឹងជម្ងឺអេដស៍ សមាជិក

៦-<u>គណៈកម្មាធិការជាតិសំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកវិទ្យាសាស្ត្រ និងបច្ចេកវិជ្ជា</u> **(National Committee on Science and Technology )**

- ប្រធានស្ថាប័ន ឬ តំណាងក្រសួង ឧស្សាហកម្ម រ៉ែ និងថាមពល ប្រធាន
- ប្រធានស្ថាប័ន ឬ តំណាង ក្រសួងអប់រំ យុវជន និងកីឡា អនុប្រធាន
- តំណាង លេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា អនុប្រធានប្រចាំការ
- តំណាងទីស្តីការគណៈរដ្ឋមន្ត្រី សមាជិក
- តំណាង ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សមាជិក
- តំណាង ក្រសួង ពាណិជ្ជកម្ម សមាជិក
- តំណាង ក្រសួង កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សមាជិក
- តំណាង ក្រសួង សាធារណការ និងដឹកជញ្ជូន សមាជិក
- តំណាង ក្រសួង ប្រៃសណីយ៍ និងទូរគមនាគមន៍ សមាជិក
- តំណាង ក្រសួង បរិស្ថាន សមាជិក
- តំណាង ក្រសួង ពត៌មាន សមាជិក
- តំណាង ក្រសួង សង្គមកិច្ចការងារបណ្តុះបណ្តាលវិជ្ជាជីវៈនិងយុវនីតិសម្បទា សមាជិក
- តំណាង ក្រសួង រៀបចំដែនដី នគរូបនីយកម្ម និងសំណង់ សមាជិក
- តំណាង ក្រសួង ធនធានទឹក និងឧតុនិយម សមាជិក
- តំណាង ក្រសួង សុខាភិបាល សមាជិក
- តំណាង រដ្ឋលេខាធិការដ្ឋាន អាកាសចរណ៍ស៊ីវិលកម្ពុជា សមាជិក

មាត្រា ៣ .-

គណៈកម្មាធិការជាតិសំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកជំនាញនីមួយៗ ត្រូវមានភារកិច្ចដូចតទៅ :

- ប្រធានគណៈកម្មាធិការជាតិសំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកជំនាញនីមួយៗ និងលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា មានតួនាទីជាអ្នកសំរបសំរួល (Focal Point) លើកិច្ចសហប្រតិបត្តិការតាមជំនាញនីមួយៗ របស់ខ្លួនជាមួយលេខាធិការដ្ឋានជាតិអាស៊ានទាំងអស់ (ASEAN National Secretariats) លេខាធិការ

ក្រុមលេខាធិការអាស៊ាន (ASEAN Secretariats) និងដៃគូប្រទេសជាដៃគូសន្ទនារបស់អាស៊ាន (ASEAN Dialogue Partners )

- ប្រធានគណៈកម្មាធិការជាតិសំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកជំនាញនីមួយៗ ចាំបាច់ត្រូវតែរាយការណ៍ពីដំណើរការកិច្ចសហប្រតិបត្តិការជំនាញទាំងអស់ទៅក្រុមលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា ដែលជាលេខាធិការរបស់ប្រព័ន្ធសំរបសំរួលផ្ទៃក្នុង (ICN )
- ពិនិត្យ និងសំរេចបញ្ហាគណៈប្រតិភូសហគ្រាសទៅចូលរួមប្រជុំ និងចូលរួមសកម្មភាពនានាតាមមុខជំនាញនីមួយៗ.
- ក្រោយពេលត្រឡប់មកវិញ គណៈប្រតិភូចូលរួមត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរ ជូនគណៈកម្មាធិការជាតិ រដ្ឋមន្ត្រីទទួលបន្ទុកកិច្ចការអាស៊ាន និងលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា ពីលទ្ធផលនៃកិច្ចប្រជុំ ។

មាត្រា ៤ .-

- សមាសភាពទាំងឡាយនៃគណៈកម្មាធិការជាតិសំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកជំនាញនីមួយៗ ត្រូវចូលរួមប្រជុំតាមការអញ្ជើញរបស់ប្រធាន
- ក្នុងករណីចាំបាច់ ប្រធានគណៈកម្មាធិការជាតិ ឬ អនុប្រធានប្រចាំការនៃប្រព័ន្ធសំរបសំរួលផ្ទៃក្នុង មានសិទ្ធិអញ្ជើញប្រធាន ឬតំណាងស្ថាប័ន ក្រសួងពាក់ព័ន្ធចូលរួមក្នុងអង្គប្រជុំ
- ក្នុងករណីចាំបាច់ សមាសភាពទាំងឡាយនៃប្រព័ន្ធសំរបសំរួលផ្ទៃក្នុង ចូលរួមក្នុងអង្គប្រជុំតាមការអញ្ជើញរបស់អនុប្រធានប្រចាំការ ។

មាត្រា ៥ .-

- កិច្ចប្រជុំរបស់គណៈកម្មាធិការជាតិសំរាប់កិច្ចសហប្រតិបត្តិការអាស៊ាននៃ ជំនាញនីមួយៗ ត្រូវប្រព្រឹត្តទៅនៅក្នុងក្រសួង ឬ ស្ថាប័នរបស់ប្រធានគណៈកម្មាធិការជាតិ ឬតាមការចាំបាច់នៅលេខាធិការដ្ឋានជាតិអាស៊ាន កម្ពុជា
- ប្រធានគណៈកម្មាធិការជាតិ សំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកជំនាញ មានសិទ្ធិប្រើប្រាស់បន្ថែមអង្គភាពអាស៊ាននៅក្នុងក្រសួង ឬ ស្ថាប័នរបស់ខ្លួន ជាលេខាធិការដ្ឋាននៃអង្គប្រជុំ ។

មាត្រា ៦ .-

- លេខាធិការដ្ឋាននៃអង្គប្រជុំ ត្រូវរាយការណ៍ជាលាយលក្ខណ៍អក្សរពីលទ្ធផលនៃកិច្ចប្រជុំ ជូនលេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា នៃក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងសមាជិកទាំងអស់នៃអង្គប្រជុំ។

មាត្រា ៧ .-

- អនុក្រឹត្យលេខ ២៧ អនក្រ.បក ស្ដីពីការបង្កើតគណៈកម្មាធិការជាតិទាំង៦ សំរាប់កិច្ចសហប្រតិបត្តិការអាស៊ានផ្នែកជំនាញ (**Functional Cooperation**) ចុះថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ ១៩៩៧ និងបទបញ្ញត្តិទាំងឡាយណាដែលផ្ទុយ ពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

www.pheakdeylaw.com

**មាត្រា ៨ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការបរទេស និង សហប្រតិបត្តិការអន្តរជាតិ លេខាធិការដ្ឋានជាតិអាស៊ានកម្ពុជា ក្រសួង និងស្ថាប័នពាក់ព័ន្ធនានា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ឱ្យមានប្រសិទ្ធភាព ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែ មេសា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

**ហ៊ុន សែន**

**បានចំរាបជូនសម្តេចនាយករដ្ឋមន្ត្រី**

**ដើម្បីចុះហត្ថលេខា**

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ**

ហត្ថលេខា

**ហោ ណាំហុង**

★★★

**អនុក្រឹត្យ លេខ ២២ អនក្រ.បក**

**ស្តីពីការបង្កើត**

**ឃុំព្រៃត្រឡាច ចំណុះស្រុកមោងឫស្សី ខេត្តបាត់ដំបង**

***

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១១៩៨/៧២ ចុះថ្ងៃទី៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងមហាផ្ទៃ
- តាមសំណើរបស់សហរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ

**សំរេច**

**មាត្រា ១ .-** ត្រូវបានបង្កើត ឃុំព្រៃត្រឡាច ចំណុះស្រុកមោងឫស្សី ខេត្តបាត់ដំបង ។

**មាត្រា ២ .-** ឃុំព្រៃត្រឡាចមានព្រំប្រទល់រដ្ឋបាល :

www.pheakdeylaw.com